អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស
## ថ្ងៃ១០ ធ្នូ ១៩៤៨ ។

www.hoksavann.org

ថ្ងៃទី២ កុម្ភៈ ២០១២



ដោយមានសំណើសុំជាច្រើន សុំឲ្យយើងចុះផ្សាយទាំងស្រុងនូវធម្មនុញ្ញនៃសិទ្ធិមនុស្ស ដែលអង្គការសហប្រជាជាតិបានប្រកាសជាសកលកាលពីថ្ងៃ១០ ធ្នូ ១៩៤៨ ។ អ្នកស្នើសុំចង់ដឹងឲ្យបានច្បាស់នូវច្បាប់សិទ្ធិមនុស្សរបស់សកលលោកនេះ ដើម្បីយកមកឆ្លុះបញ្ចាំងមើលអ្នកកាន់អំណាចរដ្ឋរបស់ប្រទេសកម្ពុជា ដែលបានចុះហត្ថលេខាទទួលគោរព តើបានគោរពបានម៉ត់ចត់ឬទេ ។ យើងសូមស្រាវជ្រាវនិងចុះផ្សាយតាមសំណើសុំ ហើយពេលនេះ យើងមិនវែកញែកទេ ទុកជូនអ្នកអានយកទៅពិចារណានិងឆ្លុះបញ្ចាំងមើលដោយខ្លួនឯង ។ មុននឹងយកមាត្រាទាំង៣០មកចុះផ្សាយ គួរដឹងអំពីបុព្វកថាខាងដើមនៃសេចក្ដីប្រកាសនៃសិទ្ធិមនុស្សនេះជាមុនសិន ។

### បុព្វកថា

- ដោយហេតុថា គ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពក្នុងពិភពលោក គឺការទទួលស្គាល់នូវសេចក្ដីថ្លៃថ្នូរជាប់ពីកំណើតមក និងនូវសិទ្ធិស្មើៗគ្នាឥតដកហូតបានរបស់មនុស្សគ្រប់រូប ។

- ដោយហេតុថា ការមិនទទួលស្គាល់និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំឲ្យកើតមាននូវអំពើព្រៃផ្សៃសាហាវយង់ឃ្នង ដែលជាទំនាស់យ៉ាងខ្លាំងដល់មនសិការមនុស្សជាតិ និងដោយហេតុថា ពិភពលោកដែលមនុស្សគ្រប់ៗរូបមានសេរីភាពក្នុងការនិយាយស្ដី ជំនឿ និងរំដោះខ្លួនឲ្យរួចផុតពីភេរវកម្មនិងទុរគតបាន ត្រូវចាត់ទុកជាសេចក្ដីប្រាថ្នាដ៏ឧត្តមរបស់មនុស្សទូទៅ ។

- ដោយហេតុថា ជាសារវន្ត សិទ្ធិមនុស្សត្រូវបានទទួលកិច្ចការពារដោយរបបធម្មាធិបតេយ្យ (យកច្បាប់ជាធំ) ដើម្បីជៀសវាងកុំឲ្យមនុស្សយកការបះបោរទៅប្រើជាមធ្យោបាយ ដើម្បីប្រឆាំងនឹងអំណាចផ្ដាច់ការ និងការសង្កត់សង្កិន ។

- ដោយហេតុថា នៅក្នុងធម្មនុញ្ញ ប្រជាពលរដ្ឋទាំងអស់នៃសហប្រជាជាតិ បានប្រកាសសាជាថ្មីម្ដងទៀត នូវជំនឿរបស់ខ្លួនទៅលើសិទ្ធិសំខាន់ៗ សេចក្ដីថ្លៃថ្នូរ តម្លៃមនុស្ស សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ហើយប្រជាពលរដ្ឋទាំងនោះបានប្រកាសដោយប្ដូរផ្ដាច់ថា នឹងជួយបង្កើនការលូតលាស់ខាងផ្លូវសង្គម ព្រមទាំងបង្កើតឲ្យមានលក្ខណៈប្រសើរ សំរាប់ការរស់នៅក្នុងសេរីភាពដ៏ទូលំទូលាយតទៅទៀត ។

- ដោយហេតុថា មានសហប្រតិបត្តិការពីអង្គការសហប្រជាជាតិផង រដ្ឋជាសមាជិកទាំងអស់បានសន្មត់ព្រមព្រៀងគ្នាបណ្ដុះបណ្ដាលឲ្យមានការគោរពជាសកល និងឲ្យបានម៉ត់ចត់នូវសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗទាំងឡាយ ។

- ដោយហេតុថា ការយល់ស្របថា សិទ្ធិនិងសេរីភាពទាំងនោះមានសារៈប្រយោជន៍ជាទីបំផុត សំរាប់ឲ្យកិច្ចព្រមព្រៀងទាំងនេះបានសំរេចពេញបរិបូរណ៍ បានជានៅពេលនេះមហាសន្និបាតប្រកាន់ថា ៖

សេចក្ដីប្រកាសសិទ្ធិមនុស្សជាសកលនេះ ជាឧត្តមគតិរួមសំរាប់ប្រជាពលរដ្ឋ និងប្រជាជាតិទាំងអស់សំរេចឡើង ដើម្បីឲ្យបុគ្គលនិងអង្គការទាំងអស់នៃសង្គមចាំជាប់ជានិច្ចនូវសេចក្ដីប្រកាសនេះ ប្រឹងបណ្ដុះបណ្ដាលឲ្យមានការគោរពសិទ្ធិនិងសេរីភាពទាំងនោះ តាមរយៈការបង្ហាត់បង្ហាញអប់រំ និងដើម្បីធានាឲ្យមានការទទួលស្គាល់ និងការអនុវត្តន៍ជាសកលឲ្យបានម៉ត់ចត់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋជាសមាជិករបស់ខ្លួនឯងផង ទាំងក្នុងចំណោមប្រជាពលរដ្ឋដែលរស់នៅក្រោមអំណាចច្បាប់របស់រដ្ឋទាំងនោះផង ដោយចាត់វិធានការទំនើបៗលើផ្នែកជាតិនិងអន្តរជាតិ ។

ការរៀបរាប់ខាងលើនេះ ជាបុព្វកថាខាងដើមនៃធម្មនុញ្ញនៃសិទ្ធិមនុស្ស ។ តទៅនេះសូមលើកយកធម្មនុញ្ញនៃសិទ្ធិមនុស្សចាប់ពីមាត្រាទី១ បានប៉ុន្មានមាត្រា តម្រូវតាមការកំណត់ក្នុងអត្ថបទនេះ ៖

★ មាត្រា១

មនុស្សទាំងអស់កើតមកមានសេរីភាព សេចក្ដីថ្លៃថ្នូរ និងសិទ្ធិស្មើៗគ្នា ។ មនុស្សគ្រប់រូបសុទ្ធតែមានវិចារណញ្ញាណនិងសតិសម្បជញ្ញៈ ហើយត្រូវប្រព្រឹត្តចំពោះគ្នាទៅវិញទៅមក ក្នុងស្មារតីរាប់អានគ្នាជាបងប្អូន ។

★ មាត្រា២

មនុស្សម្នាក់ៗសុទ្ធតែមានសិទ្ធិនិងសេរីភាពគ្រប់បែបយ៉ាងទាំងអស់ ដែលមានចែងក្នុងសេចក្ដីប្រកាសនេះ ដោយឥតប្រកាន់ជាតិសាសន៍ ពណ៌សម្បុរ ភេទ សាសនា ភាសា គោលនយោបាយ ឬមតិផ្សេងៗ ប្រភពសញ្ជាតិ ឬសង្គម ទ្រព្យសម្បត្តិ ពូជកំណើត និងស្ថានភាពដទៃផ្សេងៗទៀត ។ បន្ថែមពីនេះទៀត គប្បីកុំឲ្យមានការប្រកាន់ដោយសំអាងទៅលើលក្ខន្តិកៈនយោបាយ គតិយុត្តិធម៌ ឬលក្ខន្តិកៈអន្តរជាតិនៃប្រទេសឬដែនដី ដែលបុគ្គលមួយរូបជាអាណិកជន ទោះប្រទេសនោះជាប្រទេសឯករាជ្យ ឬស្ថិតនៅក្រោមអាណាព្យាបាល ឬក៏ពុំមានអធិបតេយ្យពេញបរិបូណ៍យ៉ាងណាក៏ដោយ ។

★ មាត្រា៣

បុគ្គលម្នាក់ៗត្រូវមានសិទ្ធិរស់នៅដោយសេរីភាព និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការការពារសន្តិសុខផ្ទាល់ខ្លួន ។

សូមបញ្ចប់នូវអត្ថបទនេះត្រឹមមាត្រាទី៣នេះ នឹងបន្តក្នុងអត្ថបទក្រោយ ។ សូមបញ្ជាក់ថា ធម្មនុញ្ញនៃសិទ្ធិមនុស្សនេះមិនមែនគោរពតែអ្នកកាន់អំណាចរដ្ឋនីមួយៗឡើយ តែមនុស្សគ្រប់រូបត្រូវគោរពទាំងអស់គ្នា ជាពិសេសគ្រប់ប្រទេសទាំងអស់ត្រូវគោរពកុំឈ្លានពានគ្នាទៅវិញទៅមក ។៚